# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត
សៀមរាប-ឧត្តរមានជ័យ
សាលក្រម
លេខ ០៣ គ ចុះថ្ងៃទី ២៤
ខែ មករា ឆ្នាំ ២០០៦
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៦៧៣ ចុះថ្ងៃទី ២១
ខែ វិច្ឆិកា ឆ្នាំ ២០០៥

សាលក្រមនេះបានចូលជាស្ថាពរនៅថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០០៦ ដោយពុំមានភាគីណាមួយបានប្តឹងឧទ្ធរណ៍ក្នុងរយៈពេលកំណត់ច្បាប់ឡើយ ។
សៀមរាប,ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៦
ក្រឡាបញ្ជី
[redacted]

ក្នុងនាមប្រជារាស្ត្រខ្មែរ
តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នាថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៦ ដោយមានសមាសភាព :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ចៅក្រមតុលាការខេត្ត

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្ត

**មេធាវី**

លោក ឌឹម ឈុនឡេង

ដើម្បីជំនុំជំរះរឿងព្រហ្មទណ្ឌលេខ ៦៧៣ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ :

-ឈ្មោះ ល ម ហៅ ពៅ ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅភូមិចុងកៅស៊ូ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី ០៨ថ្មី ទីលំនៅមុនពេលចាប់ខ្លួននៅភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប របររកស៊ីកម្មករ ប្រពន្ធឈ្មោះ ន យ ឪពុកឈ្មោះ ល មម "ស" ម្តាយឈ្មោះ ស ណ "វ" ទោសពីមុនមានជាប់ពន្ធនាគារកំណត់ ០៤ខែ ពីបទចោរកម្ម តាមអំណោចសាលក្រមលេខ ២០ ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៣ ។

ឃុំខ្លួនថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។

ត្រូវចោទពីបទ : ប្លន់ ប្រព្រឹត្តនៅភូមិវត្តបូព៌ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

-លោកមេធាវី ឌឹម ឈុនឡេង ជាអ្នកការពារសិទ្ធិជនជាប់ចោទឈ្មោះ ល ម

-ជនរងគ្រោះឈ្មោះ A R O (អេរ៉ូ អេបេក) ភេទស្រី

អាយុ ៣១ឆ្នាំ ជនជាតិអូស្ត្រាលី ស្នាក់នៅសណ្ឋាគារសេរីភាព ភូមិស្លក្រាម ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។

## ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ

កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៥ វេលាម៉ោង ០៩យប់ ឈ្មោះ **បញ្ញា** ភេទប្រុស បានខ្ចីម៉ូតូរបស់ឈ្មោះ **ធីតា** ភេទស្រី សេ១២៥ ពណ៌ក្រហម ស៊េរី ២០០៥ ជិះទៅវង្គសាលម៉ាទីនី បបួលឈ្មោះ **ល ហ** មកហាងមរកត ។ ឈ្មោះ **ល ហ** ក៏បានយល់ព្រមជិះម៉ូតូឌុបឈ្មោះ **បញ្ញា** មកតាមផ្លូវមាត់ស្ទឹងខាងកើត ។ លុះជិះមកដល់សណ្ឋាគារបាយ័នជាប់នឹងហាងតែគុជខ្លូខ្លូ ពួកគេបានឃើញស្រីជនជាតិបរទេសពីរនាក់កំពុងជិះកង់ម្នាក់មួយ ។ ម្នាក់ដាក់កាបូបនៅនឹងកន្ត្រកកង់ និង ម្នាក់ទៀតស្ពាយកាបូបពីក្រោយខ្នង ។ ពេលនោះឈ្មោះ **ល ហ** បានជិះម៉ូតូទៅកៀកអ្នកដាក់កាបូបនឹងកន្ត្រកកង់ឈ្មោះ **បញ្ញា** ក៏ឆក់កាបូបនោះបានតែម្តង ហើយជិះឆ្លងស្ពានវត្តព្រះព្រហ្មរ័ត្នកាត់មកផ្សារដើមក្រឡាញ់ ។ ចំណែកជនរងគ្រោះឈ្មោះ A R G បានមកប្តឹងសមត្ថកិច្ចឱ្យជួយរកកាបូបពណ៌ខ្មៅលាយពណ៌ពងមាន់ ដែលនៅក្នុងកាបូបនោះមានទូរស័ព្ទដៃចំនួន ០២គ្រឿង, លុយចំនួន ១០០ដុល្លា ( មួយរយដុល្លាអាមេរិក ) លុយខ្មែរចំនួន ២៥០០រុ០០ (ពីរពាន់ប្រាំរយរៀល), សៀវភៅការងារចំនួន ០២ក្បាល និង សំភារៈប្រើប្រាស់មួយចំនួនទៀត ។ ពេលជិះម៉ូតូទៅដល់ផ្សារដើមក្រឡាញ់ឈ្មោះ **បញ្ញា** ជាអ្នកពិនិត្យកាបូបបាននិយាយប្រាប់ឈ្មោះ **ល ហ** ថា ក្នុងកាបូបមានតែលុយ ៨៧ដុល្លា (ប៉ែតសិបប្រាំពីរដុល្លាអាមេរិក) ទេ ។ រួចក៏បានបោះកាបូបចោលទៅនឹងគុម្ពោតព្រៃ ដោយបានយកលុយចាយវាយអស់ហើយ ។ ឈ្មោះ **ល ហ** ត្រូវសមត្ថកិច្ចចាប់ខ្លួនបាននៅថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នៅភូមិបន្ទាយចាស់ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ **ល ហ** បានឆ្លើយថា កាលពីខែតុលា ឆ្នាំ ២០០៥ នៅវេលាម៉ោង ០៩យប់ខ្លួនបានទៅវង្គសាលម៉ាទីនី ចាំយាមម៉ូតូ ។ ឈ្មោះ **បញ្ញា** បានខ្ចីម៉ូតូពីឈ្មោះ **ធីតា** សេ១២៥ ពណ៌ក្រហម ស៊េរី២០០៥ មកបបួលខ្លួនថា ទៅហាងមរកតកន្លែងខ្លួនជួលស្នាក់នៅថា ទៅហូបបាយ ខ្លួនក៏យល់ព្រម ដោយខ្លួនជាអ្នកឌុបឈ្មោះ **បញ្ញា** មកតាមផ្លូវមាត់ស្ទឹងខាងកើត ពេលជិះមកដល់សណ្ឋាគារបាយ័នចាស់ជិតហាងតែគុជខ្លូខ្លូបានឃើញស្រីជនជាតិបរទេស ០២នាក់ កំពុងជិះកង់ម្នាក់មួយ ម្នាក់ដាក់កាបូបនឹងកន្ត្រកកង់ និង ម្នាក់ទៀតស្ពាយកាបូបនៅនឹងខ្នង ។ ពេលនោះឈ្មោះ **បញ្ញា** យោកខ្លួនឱ្យម៉ូតូចូលទៅកៀកអ្នកជិះកង់ដាក់កាបូបនឹងកន្ត្រក ដែលខ្លួនមិនបានដឹងជាមុន។ ឈ្មោះ **បញ្ញា** ឆក់កាបូបនោះបានហើយឱ្យខ្លួនជិះលឿនឆ្លងស្ពានវត្តព្រះព្រហ្មរ័ត្នកាត់មកផ្សារដើមក្រឡាញ់ ។ ឈ្មោះ **បញ្ញា** ជាអ្នកបើកឆែកកាបូបនោះថា មានលុយតែ ៨៧ដុល្លា(ប៉ែតសិបប្រាំពីរដុល្លា) ហើយវាបានបោះកាបូបចោលទៅរួចជិះត្រឡប់មកវង្គសាលសួន្សរីន ជួបម្ចាស់ម៉ូតូឱ្យ ៥ដុល្លា និង ០២ដុល្លា ចាក់សាំងសល់ចែកគ្នាម្នាក់ ៤០ដុល្លា ។

-ក្រឡាបញ្ជីអានរបាយការណ៍លេខ ១៤៧ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥ របស់នគរបាលប៉ុស្តិ៍ឃុំសាលាកំរើកបានបញ្ជាក់ថា នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៥ វេលាម៉ោង ២១:០០នាទី មានជនល្មើសមិនស្គាល់មុខភេទប្រុសចំនួន ០២នាក់ ជិះម៉ូតូឌុនសេ ១២៥ មួយគ្រឿង ធ្វើសកម្មភាពប្លន់យកកាបូបពីក្នុងកន្ត្រកកង់របស់ឈ្មោះ A R G ដែលកំពុងជិះតាមផ្លូវនៅត្រង់ចំណុចក្បែរសណ្ឋាគារបាយ័ន ( ខាងត្បូង) ភូមិវត្តបូព៌ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប បណ្តាលអោយបាត់បង់កាបូបពណ៌ខ្មៅលាយពណ៌ពងមាន់មួយ, ទូរស័ព្ទ ០២គ្រឿង, លុយ ១០០ដុល្លា, លុយខ្មែរ ២.៥០០រៀល និង សំភារៈប្រើប្រាស់មួយចំនួនទៀត របស់ឈ្មោះ A R G

ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិអូស្ត្រាលី បុគ្គលិកអង្គការស្បៀង អាហារពិភពលោកស្នាក់នៅសណ្ឋាគារសេរីភាព ។

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសួរដេញដោល និង ចម្លើយសារភាពរបស់ជនជាប់ចោទរួចមកឃើញថា ឈ្មោះ **លហ** ពិតជាបានប្រព្រឹត្តបទល្មើសប្លន់ទៅលើជនរងគ្រោះឈ្មោះ A R G ដោយបានជិះម៉ូតូទៅឆក់កាបូបដែលគេដាក់នៅក្នុងកន្ត្រកកង់ រួចជិះគេចខ្លួនបាត់រហូតដល់ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទើបសមត្ថកិច្ចចាប់ខ្លួនបាន ដូច្នេះមានពិរុទ្ធភាពធូនល្មមលើឈ្មោះ **លហ** ពីបទប្លន់ប្រព្រឹត្ត នៅភូមិវត្តបូព៌ ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៥ ។

ហេតុនេះសូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ៤៦ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៥ ទុកជាបានការពេលទាំងមូល ។

សូមតុលាការផ្តន្ទាទោសជនជាប់ចោទតាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

លោកមេធាវី **ឌឹម ឈុនឡេង** ការពារសិទ្ធិជនជាប់ចោទឈ្មោះ **លហ** បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសួរដេញដោលរួចមក កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពនូវទោសកំហុសរបស់ខ្លួនរួចហើយ ។ យោងតាមមាត្រា ៤៨ រដ្ឋធម្មនុញ្ញ, មាត្រា ៣៧ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ, មាត្រា ៦៨ ច្បាប់ព្រហ្មទណ្ឌអន្តរកាល និង សេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៥ ឃើញថា កូនក្តីខ្ញុំបាទស្ថិតនៅជាអនីតិជន ដែលច្បាប់បានផ្តល់ស្ថានទម្ងន់ទោសអោយ ដូច្នេះសូមតុលាការមេត្តាពិចារណាជួយសំរាលទោសអោយកូនក្តីខ្លួន ដោយអនុគ្រោះ ។

ជនជាប់ចោទឈ្មោះ **លហ** បាននិយាយសំដីចុងក្រោយបង្អស់ថា សូមតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-បានស្តាប់ចម្លើយជនជាប់ចោទ
-បានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ
-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ
-បានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

**<u>តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ</u>**

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>យល់ឃើញថា</u>**

-កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៥ វេលាម៉ោង ០៩យប់ឈ្មោះ **លហ** ជិះម៉ូតូសេ ១២៥ ពណ៌ក្រហមឌុបឈ្មោះ **បញ្ញា** តាមមាត់ស្ទឹងសៀមរាបខាងកើត មកដល់មុខសណ្ឋាគារបាយ័នឃើញជនរងគ្រោះកំពុងជិះកង់ មានកាបូបដាក់ក្នុងកន្ត្រកកង់ ក៏ជិះម៉ូតូឆាបទៅជិតអោយឈ្មោះ **បញ្ញា** ឆក់យកកាបូបបានមួយមានប្រាក់មួយចំនួន ដកយកហើយបោះកាបូបចោលជិះគេចខ្លួន ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ **លហ** មានចែង និង ផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

-ប៉ុន្តែបើពិនិត្យឱ្យជិតដល់ទៅឃើញថា ជនជាប់ចោទឈ្មោះ **លហ** ជាអនីតិជនពិតប្រាកដ តែជនជាប់ចោទជាយុវជនមិនរាងចាល ធ្លាប់ត្រូវតុលាការផ្តន្ទាទោសចំនួន ០៣លើកហើយ ។

## ហេតុដូច្នេះទើបវិនិច្ឆ័យសេចក្តី

១-ផ្តន្ទាទោសឈ្មោះ ឈ ហ ដាក់ពន្ធនាគារកំណត់ ០៣(បី) ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ។

ពីបទ ប្លន់ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ប្រព្រឹត្តនៅភូមិវត្តបូព៌ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៥ ។

២-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ ឈ ហ កំបាំងមុខជនរងគ្រោះ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ
ហត្ថលេខា និង ត្រា
[redacted]

ចៅក្រមជំនុំជំរះ
ហត្ថលេខា និង ត្រា
[redacted]